# រដ្ឋម៉ាសាឈូសេត្ស៍

តំបន់ Middlesex, SS. តុលាការកំពូលនៃទីក្រុងឡូវែល

លេខករណីបណ្តឹង C.A. 99-04659

**វត្តត្រៃរតនារាម** )

ភាគីដើមចោទ )

ប្តឹងចោទ )

**ព្រះភិក្ខុ កើត សម្បូរណ៍ និងសហគមន៍ព្រះសង្ឃខ្មែរ** )

ភាគីចុងចោទ

## <u>សេចក្តីផ្សះផ្សា ការបង្រួបបង្រួមគ្នា និងកិច្ចព្រមព្រៀងបញ្ចប់ជំទាន</u>

ភាគីទាំងអស់ អនុលោម (យល់ស្រប) តាមកិច្ចព្រមព្រៀង មានចែងនៅក្នុងករណីបណ្តឹងរបស់<u>វត្តត្រៃរតនារាម ប្តឹងចោទ ព្រះភិក្ខុកើត សម្បូរណ៍និងដទៃ</u> លេខក្តីក្តាំ MICV1999-04659 ។

យោងការអនុលោមតាមសេចក្តីផ្សះផ្សាវិវាទ និងក្នុងស្មារតីបង្រួបបង្រួមគ្នា ភាគីទាំងអស់យល់ព្រមដំណើរការដូចតទៅ ÷

១-សហគមន៍ព្រះសង្ឃខ្មែរ នឹងផ្ទេរកម្មសិទ្ធិ (ឈ្មោះ)នៃទ្រព្យសម្បត្តិជាក់ស្តែង ដែលស្ថិតនៅអាស័យដ្ឋាន 21 Quigley Avenue និងស្ថិតនៅ 25 Quigley Avenue នាទីក្រុង North Chelmsford រដ្ឋ Massachusetts ប្រគល់ទៅវត្តត្រៃរតនារាម ។ គម្រោងដីទាំងនោះ ត្រូវតែតម្កល់ទុកនៅក្នុងបញ្ជីតតិយជន (អាជ្ញាកណ្តាលរបស់តុលាការ) ដោយលោកមេធាវី Robert L. Burke ទម្រាំតែមានគណៈកម្មាធិការនាយកថ្មីនៃវត្តត្រៃរតនារាម ចាប់ផ្តើមបើកកិច្ចប្រជុំ (របស់ខ្លួន) យោងបទបញ្ជាតុលាការ មានចែងដូចខាងក្រោម ។ នៅពេលគណៈកម្មាធិការនាយកថ្មី បានចាប់ផ្តើមបើកកិច្ចប្រជុំដំណើរការរួចរាល់ហើយ មេធាវី Robert L. Burke ត្រូវតែចុះបញ្ជីគម្រោងដីទាំងនោះនៅឯមន្ទីរក្រឡាបញ្ជីសុរិយោដី និងអចលនទ្រព្យសម្បត្តិ Middlesex North District Registry of Deeds ។

២-គណៈកម្មាធិការនាយកថ្មីរបស់វត្ត ត្រូវតែមានសមាសភាព ដប់បី ១៣-រូប រាប់ទាំង លោក សរ ថៃល លោក ហួត សម្បត្តិ លោក Benjamin Phayso អ្នកស្រី ទេព ច័ន្ទឈឿន លោក កង ម៉ៅ លោក អួត មិត្ត លោក កង កាក់ និងលោក ជៀម យ៉ង់ ។ សមាជិកប្រាំ ៥-រូប បន្ថែមរបស់គណៈកម្មាធិការនាយកថ្មី គឺជាមនុស្សនៅក្នុងសហគមន៍ ត្រូវតែជ្រើសរើសបន្ថែម ដោយសមាជិកទាំងប្រាំបី ៨-រូប មានរៀបរាប់ខាងលើរួចមកហើយ ។

៣-សមាជិក សមាជិកាទាំងដប់បី ១៣-រូបនៃគណៈកម្មាធិការនាយកថ្មី និងព្រះភិក្ខុ សៅ ឃន ជាសម្លេងឆ្នោតទី១៤ មានសិទ្ធិបោះឆ្នោតជ្រើសតាំងព្រះគ្រូចៅអធិការប្រចាំវត្តអារាម ។ សម្លេងឆ្នោត យកជាការបាន ដើម្បីជ្រើសតាំងព្រះគ្រូចៅអធិការវត្ត គឺដប់ ១០-សម្លេង (ឬសន្លឹកឆ្នោត) ។

៤-ភាគីទាំងអស់ យល់ព្រម លះបង់សិទ្ធិទៅលើប្រាក់ចំណាយនិងកម្រៃទាំងអស់ និង លះបង់សិទ្ធិទាំងអស់ទៅលើការតវ៉ា ។

ធ្វើនៅថ្ងៃទី០៧ ខែធ្នូ គ.ស.២០០៦ ដោយក្រុមមេធាវីរបស់ភាគីពាក់ព័ន្ធទាំងអស់។

| | |
|---|---|
| ក្រុមមេធាវីភាគីចុងចោទ | ក្រុមមេធាវីភាគីដើមចោទ |
| [ ហត្ថលេខា ] | [ ហត្ថលេខា ] |
| Richard E. Brody | Douglas W. Salvesen |
| Virginia Lee | Jocelyn J. Campbell |

បកប្រែជាខេមរភាសាក្រៅផ្លូវការ នៅរដ្ឋម៉ាសាឈូសេត្ស៍ សហរដ្ឋអាមេរិក។ ឯកសារដើមជាភាសាអង់គ្លេស។

Source: www.Templenews.info